D00012

12

## សំភាសជាមួយស.ម ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ ស្រុក ព្រៃកប្បាស

យើងខ្ញុំបានធ្វើពិធីសំភាសមួយជាមួយស.ម ប្រធានទទួលឈ្នក សមាធិការអចិន្ត្រៃរបស់ស្រុក ប៉ុន្តែយើងខ្ញុំមានសំនួរមួយចំនួនមកទៀត ស.ម ស៊ា ប៊ុនថន ដែលទទួលបន្ទុកវប្បធម៌ និង ពត៌មាន របស់ស្រុក ដើម្បី និង បន្ថែមទៅលើបញ្ហាមួយចំនួន ដែលយើងខ្ញុំនៅគ្គាប់ពុំទាន់បានដឹង ដូចនេះយើងខ្ញុំ និង សួរសំនួរ ១ ខ ៗ ឆ្លើយនិងសំនួរនីមួយៗ ដើម្បីយើងខ្ញុំ និង ងាយស្គាល់បាន ស្រុកនីមួយៗ ភូមិនីមួយៗ

ស្រុកណាមួយសំខាន់ជាងគេ ដែលជើងតាមរបស់អង្គការនៅទីនេះសូមបងមានប្រសាសន៍ ? ក្នុងខេត្តតាកែវនេះ មានអង្គការចាត់តាំងសំរេចជាងគេ គឺស្រុកព្រៃកប្បាសដែលវាដាក់ថាជាស្រុក ៥៥ ក្នុងតំបន់ ៣៣ នៅទីព្រៃធ្លាជាទីតាំងស្រុក ៥៥ គឺជាអង្គការស៊ើបស្ទាក់ផ្ទាតាំងពីស្រុក ៥៥ ម្ល៉េះហើយអង្គការចាត់តាំងធំបំផុត គឺមានមេក្លោងរបស់វាគឺមេឃាតករ គឺឈ្មោះ អាចុង ដែលជាឃាតករផ្ទាល់ដៃដែនស្រុក ៥៥ នេះ ជាពិសេសគឺមាន ..ដៃជើងវា ២ នាក់ ជាគណៈកម្មាការឃុំឈ្មោះ អាវ៉ន និង ឈ្មោះ អាសៅ នៅចុងឆ្នាំ ១៩៧៨ ដែលបានទទួលផែនការសម្ងាត់ពីថ្នាក់លើ វាបញ្ជាដល់គណៈកម្មាការឃុំទាំងពីររូបឈ្មោះ អាវ៉ន និង អាសៅ ដែលជាដៃជើងយ៉ាងជំនិតរបស់វា ហើយកាចសាហាវបំផុតអាពីរនាក់នេះ ប្រើការបានទាំងស្រុង (អាឈ្មោះ វ៉ន ទទួលខុសត្រូវផ្នែកខាងត្បូងថ្នល់ជាតិ គឺស្រុក ៥៥ នេះ អាសៅ ទទួលខុសត្រូវផ្នែកខាងជើងថ្នល់ជាតិ ផែនការសម្ងាត់របស់វា គឺអោយជីកស្រះ ១ យ៉ាងធំ ជីកដែ្លងកំពង់ចត ហើយនិងភូមិឫស្សី ៗ ចង់រៀបរាប់អំពីក្រុមគ្រួសាររបស់ ចុង ហ្នឹង មើលទៅក្នុងចៅ ប្រពន្ធ និង ក្មួយរបស់គេ គេចាត់តាំងរបៀបណា សកម្មភាពយ៉ាងណាដែរចំពោះគ្រួសារ អាចុង ហ្នឹង ?

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុកព្រៃកប្បាសបន្តទៀតថា :

មុកហ្នឹងវាបងចុង ចុងវាបង ចំ អាហ្នឹងសុទ្ធតែជាគណៈកម្មការស្រុកហើយ ថ្នាក់តំបន់ភូមិភាគនិរតីយើងហ្នឹង ហើយ អាចុងជាគណៈកម្មការស្រុកយើងហ្នឹង ចំវាគេ កាន់ស្រុកនៅខាងត្រាំកក់ឯណោះចំពោះវង្សបងប្អូនគេហ្នឹង ហើយខ្ញុំពេលដែល ៧៥ ហើយហ្នឹង គេជម្លៀសទៅនៅតំបន់ស៊ីតគេ ហៅថាអង្គរបុរីនោះគឺតំបន់ថ្មី គេហៅថាតំបន់ស៊ីត ជម្លៀសប្រជាជនរួមទូទាំងពីភ្នំពេញរហូតទៅដល់ប្រជាជនមូលដ្ឋានឃុំលើហ្នឹង យកទៅភ្នំអង្គរបុរីហ្នឹង គេហៅថាតំបន់ស៊ីតកសាងទឹកដីថ្មី ហើយពេលដែលចេញពី ៧៥ ទៅហ្នឹង គឺប្រជាជនហ្នឹងពី ៧៥ រហូតដល់ ៧៩ ហ្នឹង គឺមានការវិនាសកម្ម និង ច្រើនណាស់ ខ្ញុំឃើញពិតជាក់ស្តែង ចំពោះខ្ញុំនៅហ្នឹង ចំពោះបញ្ហាទី ២ គឺប្រជាជនពី ៧៥ ចុះទៅគឺប្រជាជនរួមពីភ្នំពេញ គេដាក់ឈ្មោះប្រជាជន ១៧ មេសា ប្រជាជនមូលដ្ឋាននៅពីលើហ្នឹង គឺស្លាប់ដោយអត់បាយ ហើយក្មេង ហើយតូច តាចងាប់ដោយសារអត់បាយងាប់ដុះពិតាភ្នំដាហ្នឹង ងាប់ដោយអត់បាយ ងាប់ជិតទាំងអស់ហ្នឹង ហើយខ្លះយកទៅដាក់ជិតវាលបឹង ទើពីវាលបឹង យកទៅដាក់ជើងភ្នំទៀតលោត ការអនាម័យហ្នឹងវាលំបាកណាស់ ដុះពីជើងភ្នំហូរមកដល់ ទឹកតែក្បែរភ្នំ ផងយកទៅបបរនៅលើហាករណ៍វិញ ដូច្នេះការហូបចុកវាវេទនាណាស់ ហៅថាមហាវេទនាទឹក ពទ្ធវិញទៅប្រជាជនហ្នឹងមិនដឹងរត់ទៅណាមកណា ហើយស្លាប់នៅជិតភ្នំហ្នឹង សឹងតែអស់ប្រជាជន យូរទៅ ហើយដំបូងវា ២ - ៣ ឃុំ ហើយយូរទៅបញ្ចូលប្រជាជននៅសល់តែមួយឃុំហ្នឹងតិចទៀតផង ការវេទនារបស់ប្រជាជន ហើយសម្លាប់ប្រជាជនវិញវ៉ាមានយុទ្ធវិធីច្រើនបែបយ៉ាងណាស់ ចាំមើលខ្ញុំជំរាបជូន ជួនកាលខ្លះថាដកយកទៅលើវិញ ដើម្បីទៅរៀនសូត្រ នាយទាហានប្រជាជនណាដែលគេសង្ស័យ គេត្រូវដកមកលើវិញ ដល់ដកមកលើហ្នឹងទៅចង់ផ្តិលមនុស្ស ដល់ចង់ផ្តិលមនុស្សធ្វើសន្និបាតមួយធំនៅក្នុងវាលបឹងហ្នឹង គេធ្វើទៀងសួរគណៈកម្មការឃុំ និង ស្រុក ឈ្មោះសាន គណៈកម្មការស្រុកឈ្មោះ សាន ហ្នឹងគេហៅតំបន់ ២៣ គេនោះ សាន គេសួរប្រជាជនអ្នកណាទៅតាមប្តី ចំពោះប្រជាជនអ្នកណាទៅតាមឪពុកគេអោយទៅតាមឪពុក ម្ល៉េះហើយប្រជាជនហ្នឹងខ្លះនឹកឃើញថាប្តីទៅរៀនសូត្រ មកលើវិញ ស្រួលក៏មកតាមប្តីក៏ស្លាប់ទៅ ហើយខ្លះកូនហ្នឹងក៏មិនបានទៅតាមឪពុកម្តាយទេក៏នៅស្លាប់ និង ខ្លះទៅ

ខ្លះក៏នៅជាកុមារកំព្រានៅកន្លែងនោះទៅ ហើយប្រជាជនដែលរត់ព្រាស់ឡើងមកលើវិញ ដូចហ្វូងគោអញ្ចឹង ហើយដល់គេចាប់គឺបណ្ដើរយកមកវិញ គេបណ្ដើរយកមកកន្លែងស្វយ័តនោះវិញ ប្រជាជនហ្នឹងទាំងប្ដីប្រពន្ធពួកហ្នឹងដែលគេដាក់ស្លាក់ចាប់បានមកវិញហូរទឹកភ្នែក រាប់ហ្វូងដើរចុះមកវិញ ដួនកាលគេសម្លាប់ភាលា ដែលមេនាំរត់នឹងទៅ ប្រជាជនគេដើរបរិបកអោយនៅស្រុកឃុំ ឃុំគោកពោធិខ្លះឯណេះឯណោះ ហើយហ្វូងខ្លះដូចជាទៅព្រៃតាំអញ្ចឹង វារត់កាត់បឹងហ្នឹងទៅ មកទីព្រៃស្លឹកល្មៅអស់ហើយគេយកឡានមកដាក់យកទៅវិញអាខ្លះក៏គេសម្លាប់ទៅ អាខ្លះក៏វានៅទៅ មានម្នាក់នោះខ្ញុំដូចជាចង់ភ្លេច ប្រពន្ធគេហៅថា ជើងញ៉ាំងខ្ញើចៗ ហើយប្ដីទៅដាំដំណាំហ្នឹងរត់ រត់និងគេដែររត់ ១យប់ទល់ភ្លឺក៏នៅតែនឹងកន្លែងរោងហ្នឹង ខ្ញុំនឹងដើរទៅព្រលឹមឡើង អង្គភាពនៅជាមួយគ្នានឹងខ្ញុំថាពីតាំងងងរត់ ១យប់ទល់ភ្លឺហានបើនៅត្រឹមហ្នឹង វាវង្វេងគាត់ៗ ពួននៅគុម្ពព្រៃងគាត់ថាអាណិតកុំមាត់ មាត់ងាប់ខ្ញុំហើយរត់ ១យប់ទល់ភ្លឺវិលវង់នៅត្រង់កន្លែងនឹងរោងហ្នឹងវាវង្វេង ៗដូច្នេះការលំបាករបស់ប្រជាជននៅតំបន់ស្វយ័តរបស់អាម៉ុកហ្នឹងធ្ងន់ធ្ងរណាស់ ហើយបើប្រជាជនវៀតណាមវិញអត់សល់ទេសម្លាប់គ្មានសល់ទេខ្ទេចខ្ទីអស់ហើយ វាលំបាកខ្លាំងណាស់កន្លែងហ្នឹងកន្លែងនៅអត់ទៀងទាត់ទេ ឧទាហរណ៍ ថាទឹកឡើងទើបយកមកនៅកំភ្នំហ្នឹងគឺដេកដូចគ្នា ហ្មុងរទេះភ្លើង មួយខណ្ឌៗ ជាប់គ្នា គេធ្វើអោយតែបានអោយតែរួចពីដៃធ្វើខ្លួនយើងដល់ទឹកស្រុតអោយចុះមកនៅតាមស្រែតាមភ្លឺវិញ ទឹកឡើងទើបមកមានកូនមានចៅហ្នឹងយកមកដេកដូចជាចំរុះប្រចុកគ្នា ខ្ញុំមើលទៅដូចជាលំបាកហួសលែនលំបាកអ្នកដែលនៅរស់ហ្នឹង រួចមិនឡើងមកមូលដ្ឋានវិញរត់តែឆ្នាំហ្នឹង ប៉ុន្តែខាងលើនេះក៏គេធ្វើក្ដៅ គេមិនអោយបាយស៊ីទេ ព្រោះគេធ្វើបាបជំនាន់ហ្នឹង ខ្ញុំមើលទៅមិនដែលជំនាន់ណាដល់ជំនាន់ ប៉ុល ពត អៀង សារី ហ្នឹងទេការធ្វើបាបរបស់ប្រជាជនហូរទឹកភ្នែកជាប់ជានិច្ច រួចបើអ្នកគ្រប់គ្រងរបស់គេវិញ វាដូចជាកាចសាហាវហួសមនុស្សអក្រមនុស្ស វាដូចជាគ្មានការយុត្តិធម៌អាណិតអាសូររបស់មនុស្សទេ គឺគ្មានសោះ ហើយបើមានបងប្អូនម៉ែឪពី គេថាយើងមិនបាច់សួរទេ គេថាពេទ្យគេមានហើយ យើងមិនបាច់សួរទេ មិនបាច់សួរសោះទេម្ល៉េះ ហើយផ្ដាច់មនោសញ្ចេតនារបស់មនុស្សនិង មនុស្សហ្នឹងគឺគ្មានបានទាក់ទងទេ មានតាមួយគាត់មកពីកំពង់ស្ពឺដល់ពេលប្រពន្ធជិតស្លាប់នៅក្នុងមន្ទីរពេទ្យគាត់ទៅធ្វើបដ្ដិនៅអង្គរបុរីណោះ ប្រពន្ធថាកុំអាលទៅចាំមើលស្លាប់សិន រួចប្រធានកងគេមិនអោយនៅទៅដល់នោះត្រឹមតែម៉ោង ២ រសៀលប្រពន្ធងណេះស្លាប់ ហើយទំរាំសុំច្បាប់គេមកវិញពេលចេញពីភូមិទៅប្រពន្ធប្រាប់ថាចាំមើលខ្ញុំស្លាប់សិន "នៅក្នុងពេទ្យ" គាត់ក៏ចេញទៅដល់ពេលប្រហែលជាម៉ោង ២-៣ ប្រពន្ធក៏ស្លាប់ទៅគាត់ហ្នឹងហូរទឹកភ្នែក ទំរាំតែសុំគេបានមកវិញទាល់តែអ្នកនៅក្នុងអង្គភាពជាមួយជួយថានាយអាយជួយនិយាយទំរាំបានសុំមកយកប្រពន្ធទៅទុកដាក់ហ្នឹង ដូច្នេះការវេទនា វេទនាណាស់ខ្ញុំឃើញជាក់ស្ដែង ហើយជំនាន់ហ្នឹង ៗ សូមជំរាបសួរបងប្រធានគណៈកម្មាធិការស្រុក សូមបងជំរាបអំពីអង្គភាពចាត់តាំងដែលមានចាប់តាំងពីឆ្នាំ ១៩៧២មកម្ល៉េះតើគេចាត់តាំងយ៉ាងម្ដេច ហើយគេទទួលភារៈធ្វើអ្វីខ្លះ ហើយពេលនេះជាសង្គ្រាមជាមួយអាមេរិកកាំង ដូច្នេះតើអង្គការចាត់តាំងដំបូងនៅទីនេះ តើមានរបបបទយ៉ាងណាខ្លះ ? សូមបងរៀបរាប់ ក្នុងឆ្នាំ១៩៧២ គឺគេក្នុងអង្គការចាត់តាំងរបស់គេ ចាត់តាំងខ្សែរយៈភូមិឃុំពីស្រុករហូតដល់ភូមិឃុំ សុទ្ធតែជាកម្មាភិបាលខ្មែរយើងទេ ការចាត់តាំងសុទ្ធតែមូលដ្ឋាន ៗ តាមភូមិឃុំហ្នឹង ប៉ុន្តែថ្នាក់ដឹកនាំឃើញមកសុទ្ធតែអ្នកមកភ្នំលិច អ្នកធំៗ ហ្នឹង ដូចជាចុង ដូចជា ផាក និង ផេង្ហងៗ ទៀតសុទ្ធតែមកពីភ្នំលើនោះ ដើមឡើងចេញមកពីខ្សែក្រហមនោះ ខ្សែក្រហមសុទ្ធតែមកពីភ្នំលិច នេះតាមខ្ញុំពិនិត្យមើល ៗ ដល់ក្រោយមកទៀត វាមានការបែកបាក់សាមគ្គីជាមួយបងប្អូនយើង វៀតណាមមានការបែកបាក់សាមគ្គីគ្នាគឺបងប្អូនវៀតណាមយើងក៏នាំគ្នាថយទៅអញ្ចឹងដែរ ៗ ក្រោយពីបងប្អូនវៀតណាមយើងដកថយចេញទៅ ភារកិច្ចហ្នឹងក៏នៅលើអង្គការចាត់តាំងរបស់ ប៉ុល ពត ហ្នឹងតែម្ដង ដូចថាវាបាក់បែកគ្នាជាមួយអង្គការវៀតណាមហើយពីមុនឆ្នាំ ៧៣ ទៅហ្នឹង ចេះតែបាក់បែកហើយ ៗ ប្រជាជនដំបូងជឿវៀតដែរ ឧបមាថាគេប្រមែប្រមូលធ្វើបាតុកម្មឱ្យវៀតណាមថយ ប្រជាជនជឿវៀតដែរ ដល់តែពេលហ្នឹងទាហាន លន់ ណុល ក៏វានៅដែរ ៗ តាមផ្លូវថ្នល់ ៗ គេវាយដេញវៀតណាមចេញទៅ ប្រជាជនជឿវៀតមួយចំនួនដែរ ដល់ពេលនោះនៅលើអង្គការចាត់តាំងសមាសភាពប៉ុល ពត ទៅ ក៏គេរើសប្រជាជន

មុនដំបូងបំផុត ប្រជាជនណាប្រឆាំងអីៗ គេចេះតែយកដាក់គុកឯណេះឯណោះ ទាំងសម្លាប់ប្រជាជនហ្នឹងជាបន្តបន្ទាប់ទៅក៏ប្រជាជនមានការភិតភ័យដែរ ព្រោះបើគេមិនស្រួលសម្លាប់ដូចបើពួកទាហានលន់ ណុល ដែលវាយដេញចុះមកនោះហ្នឹងវាបន្ធូរបន្តិច បន្ធូរប្រជាជន ខ្លាចប្រជាជនរត់ទៅអស់ ដល់វាយបន្តិចទៅឧទាហរណ៍ វាយបន្ទាយ លន់ ណុល ហ្នឹងបានមកកៀរយកមកហើយ ប្រធានក្រុមប្រធានអីយកទៅភ្លិចហើយគេយកទៅហើយ ឧបមា អ្នកនៅបៀតទាហាន លន់ ណុល យកទៅហើយ ប្រធានក្រុមប្រធានភូមិដែលពួកលន់ ណុល ចង់ក្រងហើយ ប្រជាជនឯណេះក៏រិបដែរ រិបប្រជាជននៅមូលដ្ឋាន ក៏វារិបខ្លាំងដែរ គិតទៅអាយកពីនោះក៏សម្លាប់ដែរ ដូចប្រជាជនក៏រើសសាច់យកទៅសម្លាប់ដែរ ដល់វាយខិចទៅដល់ភ្នំពេញទៅអានៅឯណេះក៏រិបការតែខ្លាំង ជកហូតយកសព្វបែបយ៉ាងទាំងអស់ អាណាមាត់កមិនស្រួលមិនដាំដើមគេ គេវ៉ាលុចតែចេញមេសម្លាប់ ហើយកៀរចេញពីមេ ១០ ខ្ទង់ ២០ ខ្ទង់អីយកមកទៅខ្សែៗយកទៅខាងលិចមិនដឹងយកទៅឯណាទេ ជួនកាលអស់ ៧០ នាក់មួយភូមិទីព្រគាំ ភូមិគាំបន្តកៀរបានមកពីទាហាន លន់ ណុល គឺយកទៅលើទាំងខ្មែរអស់រលីង ហើយគ្មានសល់ទេទាំងប្រពន្ធទាំងកូន សម្រក់ទឹកភ្នែកមេម៉ាយ ទេទានាយ៉ាងម៉េចក៏ដោយយកអស់ហើយ ពីពេលដែលវាដណ្ដើមរដ្ឋអំណាចបាននោះ ដូចដល់ចុងក្រោយដល់ ៧៥ ហ្នឹង វាជម្លៀសមកហ្នឹង ៧៥ មកហ្នឹងក៏ឃើញថា ការសម្លាប់ហ្នឹង អានៅមូលដ្ឋានក៏មានបុរពីឃុំមួយទៅឃុំមួយ កម្មសិទ្ធអស់ហើយមានតែស្មុកមួយនិយាយត្រង់តែម្ដងអស់ហើយ ដូច្នេះមូលដ្ឋានក៏សម្លាប់អានេះពិបាកចំណំណាស់ ជួនកាលចិនហ្នឹងក៏វាមានសម្លាប់ដែរ វៀតណាមក៏វាសម្លាប់ដែល ១៧ មាននាយទាហាន មិននាយទាហានអីក៏វាសម្លាប់ អានេះវាសម្លាប់តែម្ដង ដូចដល់ពេលដែលវាអស់រដ្ឋអំណាចហ្នឹងទៀត ក៏វាសម្លាប់មួយសារទៀតតាមខ្ញុំមើលដែរ យើងរំដោះហើយហ្នឹងខ្ញុំចង់និយាយថាទីបញ្ចាប់ដែលត្រូវអាពតអស់រដ្ឋអំណាចហើយហ្នឹងម្ដងទៀតសម្លាប់ អាកៀរយកទៅទីព្រៃផ្សេងស្លាប់ចង់វាលពីភូមិទៅទៀតអាកៀរយកទៅ ដូចដល់គ្មានការណារត់រកគោអីតែអីរត់រកម្ដាយចាស់ដែលឯអីៗ លិចកើតហ្នឹងអាពតសង្ស័យសម្លាប់អាហ្នឹងមួយសារទៀត គិតទៅអាពតដែលទម្លាក់រដ្ឋអំណាចហ្នឹង គឺត្រូវវាសម្លាប់មួយសារទៀត វាសម្លាប់ ២-៣សារ អាពេលដំបូងកំពង់កាន់កាប់រដ្ឋអំណាច កំពុងដណ្ដើមរដ្ឋអំណាចអាហ្នឹងសម្លាប់មួយសារទៀតដល់បានរដ្ឋអំណាចហើយរើសសាច់សម្លាប់មួយសារទៀតដូចដល់ពេលអស់រដ្ឋអំណាចហើយអានេះក៏សម្លាប់មួយសារទៀត បីសារចង់វាលមនុស្ស គិតទៅបីសារដល់ចុងបំផុតដែលត្រូវអស់រដ្ឋអំណាច មុំនៅត្រង់ញៀនផ្ទើរ គោគ្មាននៅរដែណ អាពតពីទូជាប់បាញ់ថាអ្នកអស់ហ្នឹងចូលដៃជាមួយវៀតណាម តាមការពិតប្រជាជនល្អត្រង់គ្មានទៅភូមិករបស់គ្នាសុទ្ធតែជាមនុស្សល្អទៅងាប់ទទៀល នៅភូមិនេះតែម្ដង អាហ្នឹងពេលដែលដួររដ្ឋអំណាចហ្នឹង ដូចប្រជាជនកៀរទៅអត់បាយក្រហាយទឹកងាប់នៅតាមទីព្រៃភ្នំ ខ្លះពរកូនមិនរួចអី មិនរួចវាដាក់ខ្មែរទ្រៀមគិតតែពីរុញទៅដូចអាខ្លះខ្លាំងញោះកូនចោលទៅក្នុងទីព្រៃក៏មានអាខ្លះដាច់ពោះស្លាប់ក្នុងទីព្រៃភ្នំក៏មាន អ្នកខ្លះបានអង្គការបដិវត្តន៍យើងកៀរបានមកវិញក៏មាន មកស្គមៗអ្នកខ្លះស៊ីស្លឹកឈើរាប់ថ្ងៃក៏មាន នៅពេលប្រជាជនខ្លះសុខភាពស្រកស្លាប់ ជួបទាន់ពេលវេលាអង្គការបដិវត្តន៍យើងបានទៅរំដោះមកទៅ ក៏ដូចការបាត់បង់ស្លាប់ ពេលអាពតអស់រដ្ឋអំណាចនេះខ្លាំងណាស់ខ្ញុំមើលទៅដូចជារលោះមនុស្សក្នុងដំណាក់អាពត ការស្លាប់នេះគឺហួសនិស្ស័យខ្ញុំសុំជំរាបជូន ។ តើអង្គការដែលបានចាត់តាំងនៅក្នុងស្រុកឬភូមិ សូមបងបង្ហាញនៅលើផែនទីនេះដើម្បីអោយយើងខ្ញុំស្រួលយកទៅរៀបចំផែនទីមួយសារជាថ្មីបង្ហាញអំពីអង្គការចាត់តាំងនៅក្នុងស្រុកភូមិ នៅស្រុកទីព្រកបញ្ញាលនេះ ដើម្បីងាយស្រួលក្នុងការភូមិណាដែលអង្គការគេនៅ ហើយភូមិណាដែលអង្គការគេមិននៅ ហើយគេលប់ចោលក្នុងសម័យនោះ ស.ម ស៊ា ប៊ុនថន បានបន្តសំភាសតទៅទៀត : ការចាត់តាំងរបស់ស្រុក ៥៥ គឺក្នុងស្រុកទីព្រកបញ្ញាលយើងនេះ គឺមូលដ្ឋានធំគឺនៅទីព្រឈ្វានេះតែម្ដង ហើយខេមរយៈចាត់តាំងគ្រប់ឃុំទាំងអស់ចាប់ពីឃុំចា ឃុំស្នា រហូតដល់ឃុំអង្គរបូរី គឺមានអង្គការចាត់តាំងវាតាមខេមរយៈរហូត ប៉ុន្តែកន្លែងដែលធំជាងគេ គឺកំពង់ចកនេះដែលជាកន្លែងធ្វើទារុណកម្មយ៉ាងធំសំបើម គឺនៅកំពង់ចក ហើយនិងនៅភូមិឫស្សីនេះ គឺឃុំប្រាកាន និង ភូមិទីព្រឈ្វាជាមួយគ្នានេះ កន្លែងហ្នឹងជាមណ្ឌលឧក្រិដ្ឋកម្មធំណាស់ ហើយមានខេមរយៈធំមួយទៀតនៅរហូតដល់ភ្នំអង្គរបូរីនេះ គឺមានកន្លែងពិឃាដធំ ខេមរយៈចាត់តាំងគ្រប់ភូមិទាំង

..៤..

អស់អ្នកមានទុក្ខទោសទាំងប៉ុន្មានគឺយកមកកន្លែងភូមិឫស្សី ធ្វើទារុណកម្មនៅភូមិឫស្សីហើយសព្វគ្រប់បាន
បញ្ជូនមកកំពង់ចក កំពង់ចកគឺលែនទទេទាល់ណាស់ គឺដីក្រហម ធ្វើបាបប្រជាជនយើងដែលវាចោទប្រ
កាន់ អាក្រក់ថាល្អ ខ្មៅថាសនោះគឺឥតមានបេះពិចារណាគឺយកមកគុកកំពង់ចកហ្នឹង នេះគឺខ្មែរយះ
វាធំបំផុតអ្នកអង្គការធំចាត់តាំងនៅក្នុងស្រុកទីក្រពកប្សាល់ស្រុក ៥៥ គឺឈ្មោះចុង ដែលជាមេខ្លាង
ជាខ្មែរយះបងឈ្មោះអាមុំ ជាមេបញ្ជាការសឹកនៅភូមិភាគនិរតី ហើយនិងប្អូន១ទៀតឈ្មោះ
ចាំនៅក្នុងស្រុកត្រាំកក់ នៅក្នុងស្រុកទីក្រពកប្សាល់ មានបញ្ជាការនៅក្រោមអាចុងហ្នឹង ដែល
ជាអ្នកដែលដល់បំផុត គឺឈ្មោះសួត នៅភូមិឫស្សីហ្នឹង គឺកាប់សម្លាប់ឥតត្រាប្រណីទេតាមអំពើចិត្តហើយ
នៅក្នុងឆ្នាំ ៧៨ វាមានគំរោងផែនការ ៗ សួរចំណុចពីរទៀត គឺចំណុចទី ១ ការងារដោយបង្ខំ
ទៅលើប្រជាជនអោយបំផ្លាញសម្បត្តិវប្បធម៌ ហើយការងារមួយទៀត ឱ្យដឹកប្រពន្ធ័ ប្រឡាយ
តើប្រពន្ធ័ប្រឡាយនោះគេដឹកដើម្បីធ្វើផលិតកម្មមែន ឬក៏គេដឹកដើម្បីកប់មនុស្ស ? ល.ម ប្រធាន
គណៈកម្មាធិការប្រជាជនបដិវត្តន៍បន្តចម្លើយៈ សូមបញ្ជាក់ជូនអំពីបញ្ហាសម្បត្តិវប្បធម៌ជាតិយើងនេះ
ព្រោះថាតាមខ្ញុំមើលទៅគោលបំណងការបំផ្លាញនេះ ដោយគេមានគោលបំណងមួយគឺ បំផ្លាញទំនៀម
ទម្លាប់ចាស់ ព្រោះប្រជាជនគាត់ជឿប្រពៃណី បើអញ្ចឹងទេក្នុងការអនុវត្តន៍នេះគេកំទេចទាំង
ទំនៀមទម្លាប់ កំទេចទាំងបុគ្គល កំទេចទាំងសម្បត្តិវប្បធម៌របស់ប្រទេសដែលប្រជាជនគាត់ធ្លាប់
ជឿ គាត់ធ្លាប់ប្រពៃណីបុរាណរបស់គាត់មក គឺគេច្បាំងគ្រាប់សព្វទាំងអស់ និយាយរួមថាគេត្រូវ
បំផ្លាញរបស់ចាស់ចោលនិយាយរួមរហូតដល់ទៅបំផ្លាញមនុស្សចាស់ចោល កសាងមនុស្សថ្មីរបស់គេ នោះ
ក្នុងគោលគំនិតរបស់គេហ្នឹង ហើយគេអនុវត្តតាមគោលនយោបាយរបស់ម៉ៅគេ ថាសម្បត្តិវប្បធម៌
អស់ទាំងហ្នឹងគឺត្រូវគេបំផ្លាញចោល ព្រោះប្រជាជនយើងវាតែងតែជឿប្រពៃណីទាំងអស់ហ្នឹង បើ
អញ្ចឹងទេគេត្រូវវាយផ្ទះធំៗ ធ្វើជាផ្ទះសង្គមនិយម គេរុះ គេរើ រហូតដល់កន្លែងពុទ្ធសាសនាជា
ទីសក្ការៈបូជារបស់ប្រជាជន ដែលប្រជាជនជឿ ១០០% គេត្រូវបំផ្លាញចោល គេចោទប្រកាន់
ទាំងព្រះសង្ឃ ទាំងចាស់ទុំគ្រូបាអាចារ្យ ជាអ្នកជិះជាន់ពលកម្ម ជាអ្នកជិះជាន់ជីវភាព បើអញ្ចឹង
ទេគេបំផ្លាញអ្នកអស់ទាំងហ្នឹងទៅបានជាប្រជាជនយើងហ្នឹង កម្មាភិបាលយើងខ្លះ ក៏ស្រូបទៅតាមហ្នឹងទៅ
គេរើសយកតែមនុស្សដែលគេអាចបញ្ចានមនោគមវិជ្ជាហ្នឹងបាន ម្ល៉ោះហើយមនុស្សយើងជឿ ស៊ីបជឿ
ស៊ីបខ្លាំងមែនទែនទៅរហូតប្រមាថដល់មាតាបិតាទៅ វាចូលទៅអញ្ចឹងទៅនេះក្នុងមនោគមវិ-
ជ្ជារបស់គេហ្នឹង ផ្នែកវប្បធម៌របស់គេ ៗ ពីបញ្ហាដឹកប្រឡាយ ក្នុងការដឹកប្រឡាយបើតាមយោ
បល់របស់ខ្ញុំមើលគេដឹកប្រឡាយដើម្បីធ្វើផលិតកម្ម កសិកម្ម ប៉ុន្តែក្នុងការប្រជាជនធ្វើបានមកនេះធ្វើ ពុ
ទាំងយប់ទាំងថ្ងៃ មានតែផែនការធ្វើប៉ុណ្ណឹងទេ គេថាអ្វី ពុទាំងអស់វាកើតមកផ្នែកផលិតកម្ម-កសិកម្ម
ព្រោះគេជៀសគ្រឿងដូចជារបបលក្ខិភូមិក្តី របបសង្គមយើងក្តី ដែលដើរតាមប្រទីស្តនិយមលិទ្ធិម៉ៅក្តី
ចោទថាបើយើងដើរតាមលិទ្ធិបាកក្សេទ្បូនីសលុទ្ធតែពួកសេរីនិយម ដូច្នេះគេដឹកប្រឡាយនេះដើ-
ម្បីធ្វើផលិតកម្ម កសិកម្ម គ្មានអ្នកណាមួយមិនធ្វើទេ ប៉ុន្តែធ្វើបានហ្នឹង បើតាមខ្ញុំមើលប្រជាជនដែល
ធ្វើបាននោះលមណាស់ហូបមិនអស់ ប៉ុន្តែដឹកពីកន្លែងមួយទៅកន្លែងមួយ គឺវាដឹកផ្ញើទៅកន្លែងនោះ
ទៅកន្លែងនេះ យើងប្រជាជនមិនអាចនិយាយបានទេ ចង់អ្នកឯងដឹកយកទៅឱ្យចិនទាំងអស់ ហើយ
យើងឯណេះចេះតែធ្វើក៏មិនដឹង ធ្វើថាម៉េចព្រោះស្រូវនេះយើងមិនមែនជាអ្នកក្តាប់អីនេទេ អ្នក
ក្តាប់ឧបមាថ្នាដីក្រពក ដឹកប្រឡាយបានហើយក៏យើងឥតក្តាប់ទេស្រូវហ្នឹងនៅលើរដ្ឋឃុំ នៅលើតំបន់
មេថាតែចង់ គេឱ្យយើងស៊ីបបរខែណា យើងស៊ីបបរខែហ្នឹង គេឱ្យយើងស៊ីបាយខែណា យើងស៊ីបាយ
ខែហ្នឹង ដឹងតែពីធ្វើដូចគោ ដែលសំរាប់តែគេទឹម តែធ្វើបានប៉ុន្មានលរុបដូចបក្សយើងលពុថ្ងៃអត់
ទេដំនាន់នោះ ដឹងតែធ្វើទេមិនដឹងថាជៀនលៀនយ៉ាងម៉េច ស៊ីបាយប៉ុន្មានខែ ស៊ីបបរប៉ុន្មាន
ខែទេផែនការគេដាក់ទេ ហើយស្រូវនោះធ្វើបានឃើញតែគេដឹកទេ មិនដឹងគេដឹកយកទៅឱ្យ
ចិន ឬ ឱ្យពីណាអត់ដឹងទេ ទើបតែធ្វើបានវិញបើទើបធ្វើ ពុពិតប្រាកដតែដល់បានវិញស្រេចហើយ

ខ្ញុំជួបប្រទះវាប៉ុន្មានឆ្នាំដែរ ប៉ុន្មានឆ្នាំហ្នឹងអាធ្វើនោះ គឺធ្វើទៀងទាត់ណាស់ ដាន់រហាត់ទឹក ក៏ផ្សេង ម៉្យាងអោយវាដែរ ហើយនរណាដែលរកស៊ីដាន់រហាត់ទឹកភ្ជួរអីហ្នឹងផ្សេងម៉្យាងដែរ គេហៅថាម៉្យាង រផ្ទ អានោះវាធ្វើដូចម៉្យាងអញ្ចឹងដាន់ទឹក មានអ្នកក្តាប៉ីវាផ្សេងម៉្យាងអោយដូចទំរាំបាន១ម៉្យាង ឯងហត់ចង់ងាប់ហើយធ្វើម៉េចទាល់តែទ្រាំ ខ្ញុំមានធាក់រហាត់ទឹកជាមួយមេឃុំគេម្នាក់ក៏មានដែរពេលញ៉ុំ ស៊ីបាយដែក ហើយងងុយបរនាវតៗ ហើយទៅដាន់មួយថ្ងៃវាល់ល្ងាចមិនដែលលោះទេ តែទ្រាំៗទ្រាំ ទាល់តែហ៊ឹងស្លឹកត្រចៀករឹងទ្រាំខ្លាចងាប់ ។ បានថាគេធ្វើដីកប្រឡាយហ្នឹង ធ្វើកសិកម្មដែរ ក៏ប៉ុន្តែ ផលបានវិញមិនដឹងទៅឯណាទេ ដញ្ញូនពីកើតទៅលិច ពីលិចទៅកើត ចេះតែថាធ្វើឯណេះធ្វើឯណោះ ដាក់ឃ្លាំងឯណេះឯណោះ ។ ដូច្នេះប្រជាជនមិនអាចដឹងបានទេ ប៉ុន្តែសង្ស័យដែរ ប្រជាជនពិតមែន តែគេប្រថាប់ស៊ីទាំងអស់មានសិទ្ធិ ប៉ុន្តែនៅការសង្ស័យ ព្រោះថាធ្វើផលប៉ុណ្ណឹងហើយវាមិនត្រូវអត់ ទេ ប៉ុន្តែវាមិនហ៊ានដិយាយ តែនិយាយងាប់ ។ ម្ល៉ោះហើយអស់សិទ្ធិសេរីភាពរលីង ខ្ញុំសូមជូនយោបល់ ប៉ុណ្ណឹង ។ ខ្ញុំបានសួរបញ្ហាមួយអំពីទារកដ្ឋាន និង មតេយ្យ ប៉ុន្តែនៅមានការសង្ស័យ សូមបងមានប្រសាសន៍ ដើម្បីបញ្ជាក់អំពីទារកដ្ឋាន សម័យនោះតើទារកដ្ឋានរបៀបណា ? ពីព្រោះខ្ញុំបានឃើញ និង ភ្នែក ដែលបានឆ្លងកាត់ដែរនោះ គឺវាដូចជាយកកុមារទៅឃុំឃាំងបង្អត់អាហារ ហើយឱ្យស៊ីអាចម៍ឯង ។ តើនៅទីនេះមានស្ថានការណ៍បែបនេះដែរឬទេ ? សូមបងមានប្រសាសន៍ ក្នុងមតេយ្យរក្សាកុមារ តូចៗ បើតាមខ្ញុំពិនិត្យមើលឃើញថាដូចជាមានការវេទនាណាស់ ។ ឧទាហរណ៍ កុមារដែលនៅ អឹមអាយុពីមួយឆ្នាំ កុមារដែលនៅបៅដោះហ្នឹងយាយតែម្នាក់ហ្នឹងៗ ទទួលកុមារ ៣ ឬ ៤ នាក់ ដូច្នេះ កុមារហ្នឹងជួនកាលបៅដោះអ្នកនោះបន្តិច អ្នកនេះបន្តិច ។ កុមារនោះសុខភាពអត់ល្អទេស្គមៗ ជួនកាល មិនសូវទាំងរស់ទៀតផង ហើយម្យ៉ាងទៀតយាយដែលមើលកុមារនោះ មួយថ្ងៃៗ ឃើញតែលាងអាចម៍ លោះហើយ ដៃគាត់ឃើញតែលាបកកុមារទាំងអស់ ហើយបឹងតែហូបបាយមិនកើតផង ។ ព្រោះកុមារ វានៅជុំគ្នា៣ ឬ ៤ នាក់ ។ រូបកុមារស្គមៗ ពោះកំពោកៗ ម្តាយទៅធ្វើការជួនកាលមេដោះនៅ ឯណេះ ឧបមាមួយនាក់ហ្នឹងមេដោះមួយមិនដឹងទទួលកុមារប៉ុន្មានទេ ជំនាន់ហ្នឹងវាខ្វះជីវភាពទៀតផង ដូច្នេះជីវភាពកុមារនោះវាដូចជាធ្លាក់ចុះធ្ងន់ណាស់ មិនដែលសង្គមណាដល់ហ្នឹងទេ នេះយើងមើលទៅ កុមារអស់ហ្នឹងក៏មានស្លាប់ច្រើនដែរ ។ ម្យ៉ាងទៀតកុមារដែលនៅរស់ក៏សុខភាពអត់ល្អដែរ រូបយក កម្មជាមួយយាយៗ ។ យើងថាយាយមតេយ្យទៅចុះណា យាយមតេយ្យជំនាន់ហ្នឹងច្រើនហើយ ៗ វាដូច ជាលំបាកហួសនិស្ស័យ ប៉ុន្តែគាត់ចាស់ៗគ្មានកំលាំងទៅធ្វើការមិនរួច ដូច្នេះគេក៏ទុកនៅមើលកុមារ ទៅយកកម្មតែម្តង ។ យាយៗហូបបាយសឹងតែមិនកើត ប៉ុន្តែទ្រាំទំរាំតែនិងស្លាប់មិនដឹងធ្វើម្តេចព្រោះ ផែនការណ៍របស់វាគេដាក់មកហើយអាហ្នឹងធ្វើម៉េច ? ។ កុមារដែលមានវ័យពី ១ ឆ្នាំ ឬ ២ ឆ្នាំ ចំពោះ កុមារពីអាយុ ៣ ឆ្នាំ ទៅ ៦ ឆ្នាំនោះត្រូវនៅហ្វូងវា មួយហ្វូងទៀតខ្ញុំទៅមើលជួនកាលវាទៅ ស៊ីផ្លែឈើផ្លែទីព្រក្តកក៏មាន វាដែរ កុមារខ្លះទៀតយប់ព្រលប់វាអាចម៍ពាលទឹកពាលដី អាខ្លះសឹងអាចម៍ ដាក់គ្នា ។ ក្មេងដែលយកចេញពីម៉ែឳ អាយុ ៤ ឬ ៥ ឆ្នាំ លុះតែម៉ែឳកំពុងងូតទឹកឱ្យឬកាត់សក់ឱ្យ តែមើយកទៅដាក់ជាហ្វូងអញ្ចឹង រូបគ្មានអ្នកក្តាបក្តាប់ឯណាថែរក្សាពិតប្រាកដ ចៃក្បាលនោះឆ្លង ពីមួយទៅមួយហួសនិស្ស័យ រូបកុមារហ្នឹងមើលទៅ មិនដឹងជាកុមារអីទេ ។ តាមខ្ញុំមើលទៅកុមារអស់ ទាំងនោះមិនដឹងជាងូតទឹកផ្ញើរម៉ានទេ ជំនាន់ប៉ុល ពត ។ ម្នាក់ៗដូចជាស្មោកគ្រោកណាស់ ដូច្នេះ ហើយបានជាពោះកំពោកៗ ស៊ីតែបបរ សាច់ទ្រើងស្លេកៗ លឿងៗ ក៏តែបានយើងរំដោះទាន់កុំអី វិនាសកុមារអស់ ។ ប៉ុន្តែអង្គការបដិវត្តយើងឈ្លាសវៃណាស់ បានទទួលផលកុមារបីល្អ ផ្ទុយវិញយើងមើល កុមារដិះឡានមើលទៅសព្រាត សាច់ទាំងដុំៗ ជីវភាពវាគ្រប់គ្រាន់ ដូច្នេះកុមារអស់ទាំងនេះ វាលំបាកណាស់ជំនាន់ប៉ុល ពត ហ្នឹងតាមខ្ញុំមើល ។ ខ្ញុំសូមជំរាបជូនអំពីការចាត់តាំងរបស់បនប៉ុល ពត វាមានការចាត់តាំងរបស់គេដែរ ។ ឧទាហរណ៍ដូចជាវិស័យយោធាក៏មានតាមមូលដ្ឋានរហូតការ ចាត់តាំងរបស់គេហ្នឹងរឹងមាំណាស់ ហើយការផ្លាស់ប្តូរពីភូមិទៅភូមិមួយ ពីឃុំមួយទៅឃុំមួយគឺមានការផ្លាស់ ប្តូរដែរ ? ដូច្នេះអង្គការចាត់តាំងរបស់វាមានគ្រប់គ្រាន់ដែរ ។ ក៏ប៉ុន្តែឧទាហរណ៍ប្រជាជនមាន ការសង្ស័យ ឧបមាស្ថាប័នរដ្ឋរបស់វាហ្នឹងឃើញថាដូចជាវិស័យសិក្សាធិការរបស់វា ដូចជាមិនឃើញ

មានយោធា មាននគរបាលអីខ្លាំងដែរ ខាងវិស័យកសិកម្មមានដែរ ? តែដល់វិស័យវប្បធម៌មិនឃើញមាន ឧទាហរណ៍ថា ការសិក្សារៀនសូត្រហ្នឹងវា តាមឃុំនាយរាយគ្រូ និង សិស្សវាដូចតែគ្នាហ្នឹង ដូច្នេះមានប្រជាជនខ្លះ ដែលគេចេះដឹង គេចង់ដឹងពីវិស័យវប្បធម៌របស់ប្រជាជនដែរ រួចអាណា-គតទៅខ្លះក៏មាន ការរីកចំរើនជឿនលឿនដែរ អនាគតរបស់ប្រទេសជាតិវាយ៉ាងម៉េច ? ចុះបើត្រឹមថ្នាក់ទី ១២ សិស្សក៏រៀននៅហ្នឹងអីហ្នឹងចាំងអស់គ្នា មនុស្សអ្នកមានចំណេះវិជ្ជាច្រើន អាចត មិនយកទៅប្រើការអីទេ តើដល់អនាគតទៅមុខទៅនរណាធ្វើទូតទៅបរទេស នរណាធ្វើមន្ត្រីបក្ស នរណាធ្វើអី បើវាពន្លះផ្នែកវប្បធម៌អស់រលីងទៅហើយ ។ បើមើលទៅតាមមូលដ្ឋានឃុំនិយាយពី ការសិក្សារៀនសូត្រហ្នឹងវាតិចតួចណាស់ ដូច្នេះប្រជាជនគេលង់រ៉ាយអញ្ចឹងដែរក្នុងអង្គការចាត់តាំងហ្នឹង មិនដឹងជាការចាត់តាំងវិស័យវប្បធម៌ គេដាក់ដែរតែគ្រាន់តែមាន ប៉ុន្តែការអនុវត្តដាក់ស្តែងអត់មាន ដូចយើងសួរនេះ ។ ឧបមា យើងសួរនេះបើយើងនិយាយពីវប្បធម៌របស់យើង ការសិក្សារបស់ប្រជាជន កូនចៅតូចតាចអីយើងឃើញដាក់ស្តែង អានោះគ្រាន់តែដាក់មុខចុះអនាគតទៅ ឧបមាប្រទេសជាតិ បើសិនណាផ្អាកការសិក្សារៀនសូត្រតែ ១០ ឆ្នាំ ខូចមនុស្ស ១០ ឆ្នាំ មនុស្ស ១០ ឆ្នាំ ជើនិត់ម្ល៉េលលនឹកណាស់ ហើយផ្អាក ១០ ឆ្នាំ ផ្អាក ១០ឆ្នាំ មនុស្សចង់ខូចអស់មួយជំនាន់ហើយ បើអញ្ចឹងប្រជា-ជនក៏គេលង់រ៉ាយដែរ ឃើញថាអាពតពន្លះផ្នែកវប្បធម៌ការសិក្សារបស់កុមារជំនាន់ក្រោយ គឺពន្លះ ។ ប៉ុន្តែការចាត់តាំងគឺមានផ្លាស់ប្តូរពីនេះទៅនោះ ផ្លាស់ប្រធានស្រុក ផ្លាស់អីៗ ពិតជាមានផ្លាស់ប្រធានឃុំ ផ្លាស់សមាគមនារី-យុវជន គេរៀបរបស់គេមានដែរ សមាគមនារី សមាគមយុវជនខាងរដ្ឋបាលឃើញថាមានផ្លាស់ប្តូររបស់គេ ។ ប៉ុន្តែជួនកាលយូរៗ បាត់កម្មាភិបាលមួយទៅ អានេះវាមិនដឹងគ្រោះថ្នាក់យ៉ាងម៉េច ? បក្សគេលង់រ៉ាយចោទយ៉ាងម៉េច ? អាហ្នឹងមានបាត់ជាបន្តបន្ទាប់ដែរ អង្គការចាត់តាំងរបស់វាកាន់ប្រជាជនរឹងមាំណាស់ កាន់ក្តាប់ជាប់ ដំណើរណាក៏ត្រូវមានលិខិតដែរ បើគ្មានលិខិតគឺមិនអាចដើរបានទេ សឹងថាពីភូមិមួយទៅភូមិមួយ ហើយអាហ្នឹងចងសេកជាប់ហើយៗ ប្រជាជនទៅណារួចវាក្តាប់ប្រជាជនខ្លាំងណាស់ អង្គការចាត់តាំងរបស់វាមានខែស្រុះព្រួកដំបងជាវណ្ណដ៏ល្មម លួចដូនយោបល់បញ្ញើង ។ កម្មវិធីធ្វើសំភាសជាមួយបងប្រធានគណៈកម្មាធិការស្រុកទឹព្រកបរាណក៏ដូចជាបងប្រធានគណៈកម្មា-ធិការទទួលបន្ទុកអចិន្ត្រៃយ៍ ហើយនិងល.មទទួលបន្ទុកឃោសនាការ និង វប្បធម៌ស្រុក បានប្រព្រឹត្តទៅអស់រយៈពេលយ៉ាងយូរ ហើយប្រកបដោយខ្លឹមសារគួរអោយចាប់អារម្មណ៍ ដើម្បីបញ្ជាក់នូវភស្តុតាងយ៉ាងជាក់ស្តែងបំផុត ដែលយើងខ្ញុំបានដឹងពត៌មានថាអង្គការនៅទីព្រៃណា នេះជាអង្គការមួយដ៏កំពូល ហើយឃោរឃៅជាងគេ ។ នាទីយើងខ្ញុំចប់តែប៉ុណ្ណេះ ។